អត្ថបទស្រាវជ្រាវ

# គោលការណ៍

## ទូទៅ

# នៃនីតិព្រហ្មទណ្ឌ

រៀបរៀងដោយៈ ថាត ចាន់ថា

Shared by page: Mr. That Chantha
https:/www.facebook.com/thatchantha

# គោលការណ៍ទូទៅនៃនីតិព្រហ្មទណ្ឌ

បទល្មើសព្រហ្មទណ្ឌ គឺជាអំពើទាំងឡាយណាដែលធ្វើឲ្យខូចសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ឬបំពារបំពានដល់សិទ្ធិមនុស្សលើរូបរាងកាយមនុស្ស ឬធ្វើឲ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃ ហើយអំពើនោះមានចែងក្នុងច្បាប់ព្រហ្មទណ្ឌ ឬច្បាប់ដទៃទៀត ដែលឲ្យផ្តន្ទាទោសដាក់ពន្ធធនាគារ ឬពិន័យជាប្រាក់[1]។ ជាទូទៅប្រទេស ឬរដ្ឋណាក៏ដោយមិនថាប្រកាន់យករបបនយោបាយណាមួយនោះទេ ទោះបីប្រទេសសេរីនិយម ឬក៏ប្រទេសសង្គមនិយមក៏ដោយ ដើម្បីនាធាឲ្យបាននូវសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសង្គមឲ្យបានល្អនោះ គេទាមទារឲ្យមាននីតិសំរាប់គ្រប់គ្រង ហើយនីតិដែលដើរតួចំបងក្នុងការរៀបចំរៀបរយ សណ្តាប់ធ្នាប់សង្គមនោះ[2] គឺ "នីតិព្រហ្មទណ្ឌ" ។

## I. និយមន័យ

នីតិព្រហ្មទណ្ឌ គឺជានីតិមួយប្រភេទដែលប្រទេសនានា មិនអាចខ្វះបានឡើយ ទោះបីជាប្រទេសនោះមានបូរណភាពដែនដីទូលំទូលាយក្តី ឬតូចតាចក្តី[3] ។ នីតិព្រហ្មទណ្ឌ រួមចំណែកបង្កឲ្យមានស្ថានភាពអំណោយផលនានាដើម្បីធានាទំនាក់ទំនងសង្គម ឲ្យមានការរីកចំរើន ព្រមទាំងការពាររាល់ទំនាក់ទំនងទាំងនេះឲ្យរួចផុត ពីភាពមហន្តរាយ និងភាពអនាធិបតេយ្យដែលបង្កឡើងដោយជនល្មើស ។ ទំនាក់ទំនងដែលនីតិព្រហ្មទណ្ឌបានការពារនោះ គឺសិទ្ធិ និងកាតព្វកិច្ចស្របច្បាប់របស់ប្រជាពលរដ្ឋ ។ នីតិព្រហ្មទណ្ឌជាផ្នែកមួយនៃនីតិ វាចងក្រងរាល់បទបញ្ញត្តិ និងវិធាននានាក្នុងគោលបំណង៖ នីតិព្រហ្មទណ្ឌ ជាសំណុំវិធានទាំងឡាយណាដែលតំរង់ទិសទៅរកការផ្តន្ទាទោសជនល្មើស ចំពោះអំពើដែលបង្ករគ្រោះថ្នាក់ដល់សង្គម ។ គេអាចឲ្យនិមយន័យម៉្យាងទៀតថាជាសំណុំវិធានទាំងឡាយដែលកំណត់ **អំពីទោស** និង**បទល្មើស** ។ ហើយគេអាចហៅបានម៉្យាងទៀតថា នីតិព្រហ្មទណ្ឌ គឺឈរលើមូលដ្ឋាន នៃការកំណត់បទល្មើស មានន័យថានៅពេលបំពារបំពានធ្ងន់ធ្ងរចំពោះនីតិព្រហ្មទណ្ឌនេះ ទោសធ្ងន់ជាងគេគឺ **ទោសឧក្រិដ្ឋ**[4] ។

## II. ប្រភេទនៃនីតិព្រហ្មទណ្ឌ

ជាទូទៅនីតិជាតិត្រូវបានគេចែកជាពីរ ផ្នែកធំៗ គឺ៖

---

[1] មាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[2] មាត្រា ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[3] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ ទំព័រ ១ ឆ្នាំ២០១២។

[4] មាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

## ១. នីតិសាធារណៈ

ជាសំណុំវិធានទាំងឡាយណាដែលកំណត់ អំពីដំណើរការប្រព្រឹត្តរបស់រដ្ឋ ព្រមទាំងកំណត់អំពីទំនាក់ទំនងរវាងរដ្ឋ ជាមួយភ្នាក់ងាររដ្ឋ និងកំណត់អំពីទំនាក់ទំនងរវាងរដ្ឋ ជាមួយនឹងបុគ្គលឯកជនផងដែរ[5] ។ តាមនិយមន័យខាងលើ យើងអាចកំណត់បានថា ក្នុងទំនាក់ទំនងនៃនីតិសាធារណៈនេះដាច់ខាតត្រូវមាន ភាគីម្ខាងរដ្ឋ ។ នីតិសាធារណៈនេះត្រូវបានគេបែងចែក ជានីតិផ្សេងៗទៀតដូចតទៅ ៖

### ក. នីតិរដ្ឋធម្មនុញ្ញ

ជាសំណុំវិធាន ទាំងឡាយណាដែលកំណត់ អំពីដំណើរការប្រព្រឹត្តទៅនៃអង្គការរដ្ឋ ឬជាច្បាប់រៀបចំអង្គការ និងជាច្បាប់គ្រឹះរបស់ប្រទេសជាតិ ឬរដ្ឋមួយដែលអាចសរសេរជាលាយលក្ខណ៍អក្សរ ឬគ្មានសរសេរ ហើយចែងអំពីលក្ខណៈ និងគោលគំនិតនៃរដ្ឋាភិបាល[6] ។ ឧទា. ដំណើរការប្រព្រឹត្តទៅនៃរដ្ឋាភិបាលដំណើរការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា របស់រដ្ឋសភា និងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

### ខ. នីតិរដ្ឋបាល

ជាសំណុំវិធានទាំងឡាយណា ដែលកំណត់អំពីការប្រព្រឹត្តទៅរបស់រាជការ និងកំណត់អំពីទំនាក់ទំនងរវាងរាជការ ជាមួយអ្នកនៅក្រោមឱវាទ ឬអ្នកដែលត្រូវគេគ្រប់គ្រង[7] ។ ឧទាហរណ៍ៈ ក្រសួងគ្រងគ្រងលើការងាររបស់មន្ត្រីរាជការនៅក្រោមខ្សែបណ្តោយរបស់ខ្លួន នាយករដ្ឋមន្ត្រីគ្រប់គ្រងការងាររបស់ក្រសួងនានា ។ល។

### គ. នីតិព្រហ្មទណ្ឌ

ជាសំណុំវិធានទាំងឡាយណា ដែលកំណត់អំពីការដាក់ទោសទណ្ឌ ចំពោះអ្នកមិនគោរពច្បាប់នេះ[8]។ ឧទាហរណ៍ៈ ជនសំលាប់គេ ត្រូវដាក់ពន្ធនាគារ ជនដែលមិនគោរពច្បាប់ចរាចរណ៍ ត្រូវបានផាកពិន័យ ។

### ឃ. នីតិសារពើពន្ធ

ជាសំណុំវិធានទាំងឡាយណា ដែលទាក់ទងទៅនឹងការកំណត់ និងទាក់ទងទៅនឹងការប្រមូលពន្ធ។ ឧទា. ការបង់ពន្ធដារ ពន្ធលើប្រាក់ចំណេញ.....។

---

[5] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ ហ៊ាង ឡេង ទំព័រ ២។

[6] វចនានុក្រមច្បាប់របស់មូលនិធិអាស៊ី ទំព័រ ១០៣។

[7] សៀវភៅ វិទ្យាសាស្ត្ររដ្ឋបាល ទំព័រ ៨ ឆ្នាំ២០០៧ និង សៀវភៅនីតិរដ្ឋបាលទូទៅ ទំព័រ ១០ រៀបរៀងដោយលោកសាស្ត្រាចារ្យបណ្ឌិត សាយ បូរី ឆ្នាំ២០០៦។

[8] មាត្រា ២ នៃក្រមនីតីវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

## ២. នីតិឯកជន

ជាសំណុំវិធានទាំងឡាយណា ដែលកំណត់អំពីទំនាក់ទំនងរវាងឯកជន និងឯកជន[9]។ តាមន័យខាងលើនេះ យើងអាចសន្និដ្ឋានបានថានៅក្នុង នីតិឯកជននេះភាគីទាំងសងខាង សុទ្ធសឹងតែជា បុគ្គលឯកជនទាំងអស់ គ្មានភាគីណាមួយជាស្ថាប័នរដ្ឋឡើយ។ នីតិឯកជនត្រូវបានបែងចែកជាច្រើនប្រភេទផ្សេងៗគ្នាដូចតទៅៈ

### ក. នីតិរដ្ឋប្បវេណី

ជាសំណុំវិធានទាំងឡាយណា ដែលកំណត់អំពីទំនាក់ទំនងរវាងឯកជន និងឯកជនផងគ្នា ឬជាវិធានទាំងអស់នៃនីតិឯកជន ដែលដាក់ឲ្យអនុវត្តបានតែទៅលើផ្នែកសកម្មភាពដោយឡែកតែប៉ុណ្ណោះ ដូចជានីតិពាណិជ្ជកម្ម នីតិដីធ្លី......[10]។ ឧទា. ការទិញលក់ ការរៀបអាពាហ៍ពិពាហ៍ ការខ្ចីបំណុល.........។

### ខ. នីតិពាណិជ្ជកម្ម

ជាសំណុំវិធានទាំងឡាយណា ដែលកំណត់អំពីទំនាក់ទំនងរវាងពាណិជ្ជករ និងពាណិជ្ជករ[11] ។ ឧទា. ការលក់ដូររវាងក្រុមហ៊ុនមួយជាមួយក្រុមហ៊ុនមួយទៀត ការលក់មូលនិធិពាណិជកម្ម ។

### គ. នីតិការងារ

ជាបទដ្ឋានគតិយុត្តទាំងឡាយណា ដែលត្រូវយកមកអនុវត្តចំពោះទំនាក់ទំនងបុគ្គល និងទំនាក់ទំនងជាសមូហភាពនៃការងារ ដែលកើតមានរវាងនិយោជកឯកជន ឬសាធារណៈ និងកម្មករនិយោជិតដែលបំរើការងារក្រោមអំណាចរបស់និយោជក ដើម្បីទទួលបានកម្រៃ ដែលគេហៅថា “ប្រាក់ឈ្នួល”[12] ។

### ឃ. នីតិសន្តិសុខសង្គម ឬនីតិសង្គមកិច្ច

ជាសំណុំវិធានទាំងឡាយណា ដែលកំណត់អំពីទំនាក់ទំនងរវាងសន្តិសុខសង្គម ជាមួយអ្នកដែលត្រូវគេរ៉ាប់រង។ ឧទា. គ្រោះថ្នាក់ការងារ អ្នកដែលធ្វើការនៅកន្លែងដែលប៉ះពាល់ដល់សុខភាព.....។ តាមប្រព័ន្ធនីតិខាងលើ យើងសង្កេតឃើញថា នីតិព្រហ្មទណ្ឌស្ថិតនៅក្នុងចង្កោម នៃនីតិសាធារណៈនេះជាទស្សនៈបែបចាស់បុរាណ ប៉ុន្តែបើផ្អែកលើទស្សនៈ បែបថ្មីគេមិនត្រឹមតែចាត់ទុកនីតិព្រហ្មទណ្ឌ ក្នុងចង្កោមនៃនីតិសាធារណៈ

---

[9] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ រដ្ឋប្បវេណី ឆ្នាំ២០០៦។

[10] សន្ទានុក្រមបារាំង ខ្មែរ នៃពាក្យច្បាប់ ឆ្នាំ២០០៥។

[11] សៀវភៅ នីតិពាណិជ្ជកម្ម រៀបរៀងដោយលោកសាស្ត្រាចារ្យ គង់ សាផន ទំព័រ ៤ ឆ្នាំ២០១២។

[12] មាត្រា ១ នៃច្បាប់ការងារ ឆ្នាំ១៩៩៧ និង សៀវភៅ នីតិការងារ រៀបរៀងដោយលោកសាស្ត្រាចារ្យ បណ្ឌិត ហៃល ចំរើន ទំព័រ ២៧ ឆ្នាំ ២០០៥។

ប៉ុណ្ណោះទេគេក៏ចាត់ទុកវាស្ថិតនៅក្នុងនីតិឯកជនផងដែរ។ តទៅនេះគេចាត់ទុកនីតិព្រហ្មទណ្ឌស្ថិតក្នុងចង្កោមនៃនីតិចំរុះ ពោលគឺនីតិព្រហ្មទណ្ឌស្ថិតនៅចន្លោះនីតិសាធារណៈ និងនីតិឯកជនពីព្រោះវាមានភារកិច្ចការពារសណ្តាប់ធ្នាប់សង្គម ដោយផ្តន្ទាទោសជនល្មើសផង និងត្រូវគោរពសិទ្ធិសេរីភាពរបស់បុគ្គលផងដែរ។ ការថ្លឹងឲ្យស្មើរវាងផលប្រយោជន៍ទាំងសងខាង គឺផលប្រយោជន៍របស់រដ្ឋ ឬជាមួយផល ប្រយោជន៍របស់ប្រជាពលរដ្ឋ ឬបុគ្គលជាជនល្មើស។

## III. មែកធាងនៃនីតិព្រហ្មទណ្ឌ

នីតិព្រហ្មទណ្ឌត្រូវបានចែកជា ៣ សណ្ឋាន៖[13]

### ១. នីតិព្រហ្មទណ្ឌទូទៅ

ចែងអំពីគោលការណ៍ទូទៅ ដើម្បីកំណត់អំពីបទល្មើស កំណត់អំពីទោស និងរបៀបអនុវត្តទោស ឬជាកម្រងអត្ថបទច្បាប់ដែលសិក្សាអំពីគោលការណ៍ទូទៅ ដូចជា ការសិក្សាលើបទល្មើស ចំណាត់ថ្នាក់នៃបទល្មើស ចរិតលក្ខណៈនៃបទល្មើស ដំណាក់កាលនៃការ ប្រព្រឹត្តបទល្មើស ធាតុផ្សំនៃបទល្មើស និងជាពិសេសសិក្សាលើគោលការណ៍ការអនុវត្តទោស ។ ល ។

### ២. នីតិវិធីព្រហ្មទណ្ឌ

ចែងអំពីការចាត់តាំងអំណាចតុលាការជាជាន់ជាថ្នាក់ រៀបចំពិធី (របៀបរបប) ដើម្បីតម្រូវឲ្យសាលាជំរះក្តីគ្រប់ជាន់ថ្នាក់គោរព និងប្រតិបត្តិតាមនិងចែងអំពីគោលការណ៍ដែលត្រូវគោរពសិទ្ធិ និងសេរីភាពបុគ្គលដូចជាការឃាត់ខ្លួន ការឃុំខ្លួន ព្រមទាំងរៀបចំពិធីផ្សេងៗទៀត ដើម្បីត្រួតពិនិត្យការអនុវត្តច្បាប់ដោយស្ថាប័នតុលាការ។

### ៣. នីតិព្រហ្មទណ្ឌពិសេស

សិក្សាអំពីបទល្មើសព្រហ្មទណ្ឌនីមួយៗដើម្បីអនុវត្តគោលការណ៍នីតិព្រហ្មទណ្ឌទូទៅ ដូចជា ធាតុផ្សំនៃបទល្មើសនិងការកំរិតទោសជាដើម ឬជាកម្រងអត្ថបទច្បាប់ដែលសិក្សា អំពីបទល្មើស ប្រភេទបទល្មើស និងអំពីទោស ប្រភេទនៃទោស ដូចជាទោសក្នុងបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុជាដើម។ អត្ថបទច្បាប់នេះសិក្សាលើនិយមន័យ អត្ថន័យ និងធាតុផ្សំនៃបទល្មើសនីមួយៗ។ ឧ. បទរំលោភ សេពសន្ថវៈ បទបង្ករបួសស្នាម។

[13] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ ហ៊ាង ឡេង ទំព័រ ២។

សណ្ឋាននៃនីតិព្រហ្មទណ្ឌផ្សេងៗទៀតៈ[14]

### ១. នីតិព្រហ្មទណ្ឌអនីតិជន

មានវិធានពិសេសសម្រាប់អនីតិជន និងជាអាទិ៍ដោយផ្អែកលើការអប់រំឡើងវិញ និងការការពារអនីតិជន ឲ្យស្តារនីតិសម្បទាឡើងវិញ។

### ២. ឧក្រិដ្ឋវិទ្យា

សិក្សាពីមូលហេតុនៃបទល្មើសពីកត្តាទាំងឡាយនៃបាតុភូតបទល្មើស មានកត្តាសង្គម កត្តាគ្រួសារ ។ ល ។ ព្រមទាំងស្វែងរកវិធានការទប់ស្កាត់ ឬលុបបំបាត់ចោលនូវមូលហេតុទាំងនោះ។

### ៣. ឧក្រិដ្ឋនិច្ឆ័យ

ជាវិទ្យាសាស្ត្រ និងបច្ចេកទេសដែលគេប្រើប្រាស់ក្នុងប្រព័ន្ធតុលាការ ដើម្បីរកអង្គហេតុដែលជាធាតុផ្សំនៃអំពើល្មើស និងពិរុទ្ធភាពរបស់បុគ្គលដែលបានប្រព្រឹត្តបទល្មើស។ មុខវិជ្ជាដែលស្ថិតនៅក្នុងឧក្រិដ្ឋនិច្ឆ័យមាន វេជ្ជសាស្ត្រច្បាប់ នគរបាលខាងផ្នែកបច្ចេកទេស និងចិត្តសាស្ត្រ ជាដើម។

### ៤. ពន្ធនាគារសាស្ត្រ

សិក្សាពីទោសព្រហ្មទណ្ឌ វិធានក្នុងការអនុវត្តទោស វិធីសាស្ត្រដើម្បីអនុវត្តទោស និងសិក្សាផងដែរពីឧក្រិដ្ឋតិកិច្ចាវិទ្យា (វិធីសាស្ត្រពេទ្យ ឬវិធីផ្សេងទៀតដែលប្រើសម្រាប់ទប់ស្កាត់ភាព មិនរាងចាលរបស់ជនល្មើស) ។ ឧទាហរណ៍: រកមុខជំនាញឲ្យទណ្ឌិត ។

## IV. ទំនាក់ទំនងរវាងនីតិព្រហ្មទណ្ឌជាមួយវិទ្យាសាស្ត្រដទៃទៀត

១. វិទ្យាសាស្ត្រសិក្សា រកមូលហេតុដែលជំរុញ ឲ្យមានការប្រព្រឹត្តបទល្មើស និងសិក្សាអំពីចរិតលក្ខណៈរបស់ជនល្មើស ដែលគេឲ្យឈ្មោះថា **ឧក្រិដ្ឋវិទ្យា** ។
២. វិទ្យាសាស្ត្រសិក្សាអំពីបច្ចេកទេស ស្វែងរកជនប្រព្រឹត្តបទល្មើសនិងកំណត់នូវកាលៈទេសៈ ពិតប្រាកដនៃការប្រព្រឹត្តបទល្មើស ដែលគេហៅថា **ឧក្រិដ្ឋវិច្ឆ័យ** ដូចជា:

- នីតិវិជ្ជសាស្ត្រ

[14] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ ទំព័រ ៣ ឆ្នាំ២០១២។

- រកអត្តសញ្ញាណដោយពិនិត្យលើស្នាមម្រាមដៃ

៣. វិទ្យាសាស្ត្រសិក្សាអំពី ចិត្តសាស្ត្រអាចផ្តល់នូវការពិចារណា យល់ដឹងឲ្យបានល្អិតល្អន់ លើបុគ្គល ប្រព្រឹត្តល្មើសដែលគេឲ្យឈ្មោះថា **ចិត្តវិទ្យា** ។

៤. វិទ្យាសាស្ត្រសិក្សាអំពីមនុស្ស និងអំពីសង្គម ដែលនាំឲ្យគេថ្លឹងថ្លែងបានល្អត្រឹមត្រូវ ដែលគេហៅថា **សង្គមវិទ្យា** ។

## V. ចរិតនៃនីតិព្រហ្មទណ្ឌ

ជាទូទៅនៃនីតិព្រហ្មទណ្ឌ គឺជាការផ្តន្ទាទោសទៅលើជនល្មើសនៅពេលមានបទល្មើសមួយកើតឡើង។ ការដាក់ទោសនេះជាតំណាក់កាលមួយយ៉ាងសំខាន់គឺត្រូវផ្អែកលើមូលដ្ឋាននៃពិរុទ្ធភាពរបស់ជនល្មើសនិងកំរិតគ្រោះថ្នាក់ដល់សង្គម នៃអំពើល្មើសនោះ ។ ប្រសិនបើកំរិតគ្រោះថ្នាក់ដល់សង្គម នោះមានទំហំធំធេងទណ្ឌកម្មក៏ធ្ងន់ធ្ងរទៅតាមនោះដែរ។ ផ្ទុយទៅវិញ បើទំហំនៃការខូចខាតតិចតួចស្តួចស្តើងទេនោះទណ្ឌកម្មក៏ស្រាលទៅតាមនោះដែរ។ ចរិតនៃនីតិព្រហ្មទណ្ឌតែងតែផ្តន្ទាទោសទៅលើជនល្មើសនូវទណ្ឌកម្មពីរប្រភេទៈ

### ១. ទណ្ឌកម្មព្រហ្មទណ្ឌ

គឺជាការសម្រេចដាក់ទណ្ឌកម្មដោយស្ថាប័នតុលាការ តាមរូបភាពជាសាលក្រម ដោយយកទណ្ឌិត ទៅដាក់ពន្ធនាគារ តាមការបញ្ញត្តិរបស់ច្បាប់។ ឧទាហរណ៍ៈ មាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ បានបញ្ញត្តិថាអំពើលួចត្រូវផ្តន្ទាទោស ដាក់គុកជាបទមជ្ឈឹមពី ៦ខែ ទៅ ៣ឆ្នាំ ។

- អំពើមនុស្សឃាតដោយចេតនា មាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ បានបញ្ញត្តិថាអំពើនេះ ត្រូវផ្តន្ទាទោសពីបទឧក្រិដ្ឋដាក់គុកពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ ។
- អំពើរំលោភសេពសន្ថវៈ មាត្រា ២៣៩ នៃច្បាប់ដដែល បានបញ្ញត្តិថាអំពើនេះ ត្រូវផ្តន្ទាទោស ដាក់គុកពី ៥ឆ្នាំទៅ ១០ឆ្នាំ ។ ក្នុងករណី ដែលមានស្ថានទម្ងន់ទោសដាក់គុកជាបទឧក្រិដ្ឋពី ៧ឆ្នាំ ទៅ ១៥ឆ្នាំ ។

### ២. ទណ្ឌកម្មរដ្ឋប្បវេណី

គឺជាប្រភេទទណ្ឌកម្មមួយ ដែលច្បាប់ចាប់បង្ខំជនល្មើសឲ្យធ្វើសំណងជួសជុលការខូចខាត ដល់ប្រយោជន៍អ្នកដ៏ទៃ[15]។ ឧទាហរណ៍ៈ ករណីចោរលួចម៉ូតូម្ចាស់ម៉ូតូ ដែលជាជនរងគ្រោះមានសិទ្ធិទាមទារម៉ូតូរបស់ខ្លួនមកវិញ

[15] សៀវភៅ នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ និង លោកស្រី ចាំង ស៊ីណាត ទំព័រ៣ ឆ្នាំ២០១៥។

ព្រមទាំងសំណងជំងឺចិត្តទៀតផង។ សរុបសេចក្តីមកចរិតនៃនីតិព្រហ្មទណ្ឌ បានផ្តន្ទាទោសលើជនល្មើសនូវទណ្ឌកម្មព្រហ្មទណ្ឌផង និងទណ្ឌកម្មរដ្ឋប្បវេណីផងនោះជាការត្រឹមត្រូវណាស់ពីព្រោះការធ្វើដូចនេះអាចធ្វើឲ្យជនល្មើសខ្លាចរអា។ ពោលគឺនៅពេលដែលគេប្រព្រឹត្តបទល្មើស គេត្រូវទទួលការខាតបង់ប្រយោជន៍យ៉ាងច្រើន។ ដូចជាគេត្រូវជាប់ពន្ធនាគារមិនបានប្រកបអាជីវកម្ម ចិញ្ចឹមគ្រួសារផងព្រមទាំងត្រូវបង់សំណងដល់ជនរងគ្រោះទៀត។ ផ្ទុយទៅវិញប្រសិនបើ ច្បាប់គ្រាន់តែតម្រូវឲ្យដាក់ពន្ធនាគារមួយមុខនោះជនល្មើសមិនសូវមានការភ័យខ្លាចទេ ដូចជាករណីលួចលុយរដ្ឋ ចំនួនច្រើនបើតុលាការគ្រាន់តែដាក់ពន្ធនាគារ ក្រោយពីទទួលទោសគ្រប់ចំនួនហើយជននោះនឹងក្លាយទៅជាអ្នកមានដោយសារប្រាក់ចំនួនដ៏ច្រើនដែលខ្លួនបានលួចសម្បត្តិរដ្ឋ។ ប៉ុន្តែប្រសិនបើ គ្រាន់តែផ្តន្ទាទោសនូវសំណងរដ្ឋប្បវេណីនោះ ជនល្មើសរិតតែមិនខ្លាចរអាទៅទៀត ពីព្រោះនៅពេលដែលគេទាន់គ្រាន់តែសងចំនួនទឹកប្រាក់ នោះវិញជាការស្រេច។

## VI. ការបង្ហាញនូវរចនាសម្ព័ន្ធនានា របស់សាលាជំរះក្តីព្រហ្មទណ្ឌ

នៅពេលមានបទល្មើសមួយកើតឡើងជនល្មើស នឹងត្រូវគេផ្តន្ទាទោសដាក់ពន្ធនាគារ ប៉ុន្តែនឹងទទួលទោសនេះត្រូវឆ្លងកាត់អង្គការតុលាការ តាមលំដាប់លំដោយដូចមានចែងក្នុងច្បាប់។

### ១. តុលាការជាន់ទាប

តុលាការជាន់ទាប ជាសាលាជំរះក្តីថ្នាក់ដំបូង ដែលតាំងនៅគ្រប់ខេត្ត-ក្រុង នៃព្រះរាជាណាចក្រកម្ពុជា និងសាលាជំរះក្តីយោធា។

### ក. តុលាការខេត្ត-ក្រុង (សាលាដំបូង)

តុលាការនេះមាននៅគ្រប់ខេត្ត-ក្រុង ទាំងអស់ហើយមានតួនាទី និងសមត្ថកិច្ចជំរះក្តីលើបញ្ហាទាំងឡាយណាដែលទាក់ទងនឹងរឿងព្រហ្មទណ្ឌ រឿងរដ្ឋប្បវេណី រឿងក្តីពាណិជ្ជកម្ម វិវាទរដ្ឋបាល និងវិវាទការងារដោយបើកផ្លូវឧទ្ធរណ៍។ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា១២៨ ថ្មី វាក្យខណ្ឌទី៣ "អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផងដែរ"។ តុលាការខេត្ត-ក្រុងជំនុំជំរះដោយមានចៅក្រមម្នាក់ និងត្រូវបំពេញដោយព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងម្នាក់ និងក្រលាបញ្ជីម្នាក់។ សាលក្រមសម្រេចសេចក្តីចំពោះមុខរបស់តុលាការខេត្ត-ក្រុង បើផ្លូវប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ១ខែ គិតពីថ្ងៃកាត់សេចក្តី។ ឯសាលក្រមកំបាំងមុខបើកឲ្យប្តឹងជំទាស់ក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលដំណឹង[16]។ ការប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវតែធ្វើក្នុងរយៈពេល ១ខែ[17]

[16] មាត្រា ៣៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[17] មាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

។ បណ្តឹងឧទ្ធរណ៍ មានសុពលភាពផ្អាកជាបណ្តោះអាសន្ននូវការអនុវត្តសាលក្រម ដែលបណ្តឹងនេះត្រូវធ្វើនៅសាលាជំរះក្តីដែលបានចេញសាលក្រមនោះ[18]។ បុគ្គលដែលមានសិទ្ធិប្តឹងឧទ្ធរណ៍ ប្តឹងជំទាស់ គឺ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពិរុទ្ធជន ឬជនទាំងឡាយដែលមានប្រយោជន៍ក្នុងរឿងក្តី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី[19] ។

### ខ. តុលាការយោធា

តុលាការយោធា មានសមត្ថកិច្ចជំនុំជំរះនូវបទល្មើសយោធា ។ បទល្មើសយោធា ជាបទល្មើសដែលប្រព្រឹត្តដោយយោធិននៅក្នុងជួរកងទ័ព ឬប៉ះពាល់ដល់ទ្រព្យសម្បត្តិកងកំលាំងប្រដាប់អាវុធ ។ ករណីយោធិនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌសាមញ្ញត្រូវ តុលាការខេត្ត-ក្រុងជំនុំជំរះ ។ នីតិវិធីនៃការប្តឹងឧទ្ធរណ៍ និងនីតិវិធីជំនុំជំរះរបស់តុលាការយោធា ដូចគ្នានឹងតុលាការ ខេត្ត-ក្រុង ។

## ២. តុលាការជាន់ខ្ពស់

គួរបញ្ជាក់ផងដែរថា នៅក្នុងស្ថាប័នតុលាការជាន់ខ្ពស់ ឋានានុក្រម និងរចនាសម្ព័ន្ធរបស់តុលាការនេះ គឺត្រូវបានបែងចែងជា សាលាឧទ្ធរណ៍ និងតុលាការកំពូល ឬសាលាវិនិច្ឆ័យ ។

### ក. សាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍ មានសមត្ថកិច្ចជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ អំពីសាលក្រមរបស់តុលាការជាន់ទាប ដោយបើកផ្លូវឲ្យបណ្តឹងសាទុក្ខ។ ការជំនុំជំរះនៅសាលាឧទ្ធរណ៍ ត្រូវមានចៅក្រម ៣នាក់ ដែលមានម្នាក់ជាប្រធាន ហើយអមដោយអគ្គព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាម្នាក់នៃមហាអយ្យការ និងក្រឡាបញ្ជីម្នាក់។ ករណីមានការជំនុំជំរះសាជាថ្មី ចៅក្រមដែលបានជំនុំជំរះលើកមុនទាំង ៣រូប ត្រូវធ្វើការផ្លាស់ប្តូរថ្មី។ ករណីមានការជំនុំជំរះសាជាថ្មី ចៅក្រមដែលបានជំនុំជំរះលើកមុនអាចប្តឹងសារទុក្ខបានរយៈពេល ២ខែ គិតចាប់ពីថ្ងៃកាត់សេចក្តី ឯសាលដីកាកំបាំងមុខអាចប្តឹងជំទាស់បានក្នុងរយៈពេល ១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹង។ បើផុតរយៈពេលប្តឹងទាស់អាចប្តឹងសាទុក្ខបានក្នុងរយៈពេល ២ខែ គិតចាប់ពីថ្ងៃផុតកំណត់ប្តឹងជំទាស់[20]។ បណ្តឹងសាទុក្ខ អាចមានសុពលភាពផ្អាកជាបណ្តោះអាសន្ន នូវការអនុវត្តសាលដីការបស់ សាលាឧទ្ធរណ៍ ប៉ុន្តែបណ្តឹងសាទុក្ខដែលពាក់ព័ន្ធដល់ការឃុំខ្លួនជាបណ្តោះអាសន្នការដាក់ឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ការតំកល់រឿងទុកមិនចាត់ការ និងការលើកលែងចោទប្រកាន់ពុំមានអានុភាពផ្អាកការអនុវត្តសាល

[18] មាត្រា ៣៧៣ នៃក្រមនីតីវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[19] មាត្រា ៣៧៥ នៃក្រមនីតីវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[20] មាត្រា ៤២០ នៃក្រមនីតីវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ដីកាសាលាឧទ្ធរណ៍ឡើយ។ បណ្តឹងសាទុក្ខត្រូវធ្វើនៅ សាលាជំនុំជំរះក្តី ដែលបានចេញសាលដីកានេះ។ អ្នកដែលមានសិទ្ធិប្តឹងសាទុក្ខ និងប្តឹងជំទាស់ គឺ អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ឬអ្នកដែលមានប្រយោជន៍ក្នុងរឿងក្តី ដូចបានរៀបរាប់នៅក្នុង តុលាការខេត្ត-ក្រុង។

## ខ. តុលាការកំពូល

តុលាការកំពូល ជំនុំជំរះលើបណ្តឹងសាទុក្ខ អំពីសាលដីការរបស់តុលាការសាលាឧទ្ធរណ៍ដោយជំនុំជំរះតែលើអង្គហេតុទេ ដែលជំណាក់កាលនេះមានចៅក្រមចំនួន ៥រូប ហើយ ១រូប ជាប្រធាន។ ករណីដែលមាន បណ្តឹងសាទុក្ខទីពីរ តុលាការកំពូលត្រូវជំនុំជំរះរួមក្រុម ដោយជំនុំជំរះទាំងអង្គហេតុ និងអង្គច្បាប់ មានចៅក្រមចំនួន ៩រូប ដែលមាន ១រូប ជាប្រធាន និងគ្រប់ដំណាក់កាលជំនុំជំរះអមដោយអគ្គព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញារង និងក្រលាបញ្ជីម្នាក់។ បណ្តឹងសើរើ អាចធ្វើបានចំពោះសាលក្រម ឬសាលដីកាស្ថាពរដែលមានអំណាចដាច់ខាតហើយ បណ្តឹងធ្វើបានក្នុងរឿងមជ្ឈឹម និងរឿងឧក្រិដ្ឋ និងក្នុងករណីមួយចំនួនដែលមានចែងក្នុងច្បាប់។ បណ្តឹងសើរើមិនអាចធ្វើទេចំពោះសាលក្រម ឬសាលដីកាដែលសំរេចឲ្យរួចខ្លួន។ អ្នកដែលអាចបណ្តឹងសើរើបានគឺ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ទណ្ឌិត ឬតំណាងស្របច្បាប់របស់ជនជាប់ចោទ សហព័ន្ធ ឪពុកម្តាយ កូនរបស់ជនជាប់ចោទ និយាយរួមជនដែលមានប្រយោជន៍ខាងផ្នែកសំភារៈ ឬខាងផ្លូវចិត្ត[21]។

## សេចក្តីសន្និដ្ឋាន

នីតិព្រហ្មទណ្ឌទូទៅ គឺជានីតិម៉្យាងដែលមានបំណងការពារសណ្តាប់ធ្នាប់សង្គម និងរបៀបរៀបរយរបស់រដ្ឋដោយប្រើនូវវិធានការផ្សេងៗដែលមានលក្ខណៈកែលំអរផង និងបង្ក្រាបផង។ ទំនាក់ទំនងដែលនីតិព្រហ្មទណ្ឌបានការពារនោះ គឺ សិទ្ធិ និងកាតព្វកិច្ចស្របច្បាប់របស់ប្រជាពលរដ្ឋ ហើយនីតិព្រហ្មទណ្ឌជាផ្នែកមួយនៃនីតិនានា ដែលវាចងក្រងរាល់បទបញ្ញត្តិ និងវិធាននានា។ លើសពីនេះទៀត នីតិព្រហ្មទណ្ឌក៏មានភារកិច្ចផងដែរ ក្នុងការផ្តន្ទាទោសជនល្មើស ក្នុងនាមជាអ្នកការពារសណ្តាប់ធ្នាប់សង្គមទាំងមូល។ ទន្ទឹមនឹងនោះដែរ នីតិនេះក៏បានគោរពសិទ្ធិ និងសេរីភាពរបស់បុគ្គលជនល្មើសផងដែរ។

[21] មាត្រា ៨៤៦ នៃក្រមនីតីវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

## គន្ថនិទ្ទេសសង្ខេប

### I/ ឯកសារច្បាប់៖

1. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ។
2. ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ។
3. ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ។

### II/ សទ្ទានុក្រមដែលយកមកធ្វើជាមូលដ្ឋាន៖

1. វចនានុក្រមច្បាប់របស់មូលនិធិអាស៊ី (Asia Foundation) ។
2. សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ រដ្ឋប្បវេណី ឆ្នាំ២០០៦ ។
3. សទ្ទានុក្រមបារាំង-ខ្មែរ ពាក្យច្បាប់ ឆ្នាំ២០០៥ ។

### III/ សៀវភៅសំខាន់ៗដែលបានយកមកសិក្សា៖

1. សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ ឆ្នាំ២០១២ ។
2. សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ ហ៊ាង ឡេង ។
3. សៀវភៅ វិទ្យាសាស្ត្ររដ្ឋបាល ឆ្នាំ២០០៧ និង សៀវភៅនីតិរដ្ឋបាលទូទៅ ឆ្នាំ២០០៦ រៀបរៀងដោយលោកសាស្ត្រាចារ្យ បណ្ឌិត សាយ បូរី ។
4. សៀវភៅ នីតិពាណិជ្ជកម្ម រៀបរៀងដោយលោកសាស្ត្រាចារ្យ គង់ សាផន ឆ្នាំ២០១២ ។
5. សៀវភៅ នីតិការងារ រៀបរៀងដោយលោកសាស្ត្រាចារ្យ បណ្ឌិត ហ៊ែល ចំរើន ឆ្នាំ ២០០៥ ។
6. សៀវភៅ នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ និង លោកស្រីសាស្ត្រចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៥ ។

**ចប់**